**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

សាលក្រមព្រហ្មទណ្ឌ
លេខ ៦៧ "ខ"/ ៦៩១
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ: ១១៧៩
ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ: ៣៥២
ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅសាលសវនាការលេខ: ក១ នៃសាលាដំបូងខេត្តសៀមរាប នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង០៨ និង៣០នាទី ព្រឹក ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើ៖ សំណុំរឿងព្រហ្មទណ្ឌលេខ ១១៧៩ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ដែលមានជនជាប់ចោទដូចខាងក្រោម៖

-ឈ្មោះ [redacted] ជុន ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ កើតនៅ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន[redacted] ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] រ័ត្ន មានកូនចំនួន០៣នាក់ ឪពុកឈ្មោះ [redacted] លាប (ស) ម្តាយឈ្មោះ [redacted] ទិត (រ) ទោសពីមុនគ្មាន។

(ក្រៅឃុំ) តាមដីកាសម្រេចមិនឃុំខ្លួនលេខ ១១១២ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២

ជាប់ចោទពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិផ្លិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃឃាត់ខ្លួន បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ជុន

ភាគីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមឌី ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិធម្មជាតិសម្តេចតេជោហ៊ុនសែន ឃុំស្រអែម ស្រុកជាំក្សាន ខេត្តព្រះវិហារ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមឌី ។

**អង្គហេតុបានចោទប្រកាន់មានដូចតទៅ:**

កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្ថិតនៅចំណុចភូមិផ្លិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប មានជនសង្ស័យឈ្មោះ [redacted] ជុន ភេទប្រុស អាយុ៤១ឆ្នាំ បានណែនាំទៅកាន់ជនរងគ្រោះឈ្មោះ [redacted] សាមឌី ភេទប្រុស អាយុ៤៩ឆ្នាំ ថាខ្លួនស្គាល់ប្រជាពលរដ្ឋមានលក់ដីមួយកន្លែងទំហំ៣០០,០០០ម៉ែត្រការ៉េ ស្មើនិង៣០ហិកតា ក្នុងតម្លៃ២៣០០ដុល្លារអាមេរិកក្នុងមួយហិកតា សរុបទឹកប្រាក់ចំនួន៦៩,០០០ដុល្លារអាមេរិក ហើយជនរងគ្រោះក៏បានយល់ព្រមទិញដីខាងលើដោយឈ្មោះ [redacted] ជុន បានតម្រូវឲ្យជនរងគ្រោះឈ្មោះ [redacted] សាមឌី ប្រគល់ប្រាក់មកខ្លួនដើម្បីយកទៅកក់ដីខាងលើ។ ដោយមានការជឿទុក

Scanned with
CamScanner

ចិត្តទើបជនរងគ្រោះឈ្មោះ [redacted] សាមឌី បានប្រគល់ប្រាក់ជាបន្តបន្ទាប់ឱ្យទៅឈ្មោះ [redacted] ដុន ដើម្បីឱ្យថ្លៃទិញដីនោះ។ ក្រោយពេលដែលជនសង្ស័យឈ្មោះ [redacted] ដុន បានទទួលប្រាក់រួចហើយ គឺមិនបានយកប្រាក់ទាំងអស់ទៅកក់ថ្លៃដីឱ្យជនរងគ្រោះនោះទេ ហើយតាមចម្លើយរបស់ជនសង្ស័យឈ្មោះ [redacted] ដុន បានឆ្លើយប្រាប់ថាប្រាក់ដែលខ្លួនទទួលបានពីជនរងគ្រោះឈ្មោះ [redacted] សាមឌី សម្រាប់កក់ និងទិញដីខាងលើសរុបចំនួន ២១,០០០ដុល្លារអាមេរិក ដោយក្នុងនោះជនសង្ស័យឈ្មោះ [redacted] ដុន បានយកប្រាក់ចំនួន៥៣០០ដុល្លារអាមេរិក ទៅកក់ថ្លៃដី ហើយប្រាក់ដែលនៅសល់ជនសង្ស័យបានយកទៅទិញដី៣ទីតាំងផ្សេងទៀត និងបានយកប្រាក់មួយចំនួនទៅចាយវាយផ្ទាល់ខ្លួនដោយពុំបានប្រាប់ទៅជនរងគ្រោះឡើយ។

បានឃើញ របាយការណ៍សំយោគលេខ ៣០៣/០២២ ព្រ.ទ.ក.ធ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៨ អយណ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ ២២១០ ពស.ព្រស/ជ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប។

**<u>នាពេលសវនាការ</u>**

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដុន បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] សាមឌី ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ តាមរយៈឈ្មោះ [redacted] ដន ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មិនស្គាល់ទីលំនៅពិតប្រាកដបានណែនាំឱ្យស្គាល់ឈ្មោះ [redacted] សាមឌី បន្ទាប់មកនៅថ្ងៃទី២៦ ខែមករា ឆ្នាំ ២០២២ ខ្លួនបានដឹងថាប្រជាពលរដ្ឋមានលក់ដីមួយកន្លែងទំហំ៣០០,០០០ម៉ែត្រការ៉េស្មើនឹង៣០ហិកតា ក្នុងតម្លៃ២,៣០០ដុល្លាអាមេរិក ក្នុងមួយហិកតាសរុបទឹកប្រាក់ចំនួន៦៩,០០០ដុល្លាអាមេរិក ហើយឈ្មោះ [redacted] សាមឌី ក៏បានយល់ព្រមទិញដីខាងលើដោយខ្លួនបានតម្រូវឱ្យឈ្មោះ [redacted] សាមឌីប្រគល់ប្រាក់មកខ្លួនលើកទី១ ចំនួន៥,០០០ដុល្លាអាមេរិក ដោយខ្លួនមិនបានចាំថ្ងៃខែឆ្នាំប្រគល់នោះទេ។ នៅពេលដែលខ្លួនបានទទួលប្រាក់លើកទី១ ចំនួន៥,០០០ ដុល្លាអាមេរិក ពីឈ្មោះ [redacted] សាមឌី ខ្លួនបានយកទៅកក់ឱ្យម្ចាស់ដីឈ្មោះ លុន ហើយម្ចាស់ដីឈ្មោះ លុន បានតម្រូវឱ្យខ្លួនធ្វើយ៉ាងណាឱ្យកក់បានចំនួន៥០ភាគរយ ក្នុងរយៈពេល១ខែកន្លះ ខ្លួនបានប្រាប់ឈ្មោះ [redacted] សាមឌី ពីរឿងការបង់នោះរួចហើយ។ រំលងបានមួយអាទិត្យ ឈ្មោះ [redacted] សាមឌី បានយកប្រាក់មកឱ្យខ្លួនលើកទី២ ចំនួន២,០០០ដុល្លារអាមេរិក ដើម្បីយកទៅឱ្យម្ចាស់ដី ហើយម្ចាស់ដីមិនព្រមទទួលយក ខ្លួនក៏បានរាយការណ៍ប្រាប់ឈ្មោះ [redacted] សាមឌី ពីរឿងនិងរួចហើយដែរ ដោយម្ចាស់ដីថាបើមិនបាន៥០ភាគរយ មិនទទួលយកទេ ក្រោយមករំលងបាន១០ថ្ងៃ ឈ្មោះ [redacted] សាមឌី បានយកប្រាក់មកឱ្យខ្លួនជាលើកទី៣ ចំនួន៤,០០០ដុល្លាអាមេរិក ខ្លួនបានយកប្រាក់នោះទៅឱ្យម្ចាស់ដីមិនទទួលយកទេ ដោយទាមទារឱ្យបានចំនួន៥០ភាគរយ ទើបយកខ្លួនបានរាយការណ៍ជូនឈ្មោះ [redacted] សាមឌី រួចហើយដែរ។ ហើយរំលងរយៈពេល១ខែទើបឈ្មោះ [redacted] សាមឌី បានយកប្រាក់មកឱ្យខ្លួនជាលើកទី៤ ចំនួន១០,០០០ដុល្លាអាមេរិក ខ្លួនបានយកប្រាក់លើកទី២ លើកទី៣ និងលើកទី៤ សរុបចំនួន១៦,០០០ដុល្លាអាមេរិក ឱ្យទៅម្ចាស់ដីឈ្មោះ លុន តែគាត់មិនព្រមយកទេ ដោយម្ចាស់និយាយថាផុតរយៈពេលបង់ចំនួន៥០ភាគរយ នោះហើយម្ចាស់ដីបាននិយាយថាគាត់ឈប់លក់ទៀតហើយ ហើយចំពោះប្រាក់កក់លើកទី១ ចំនួន៥,៣០០ដុល្លាអាមេរិកបូកនឹងប្រាក់ដែលជាលុយខ្លួនផ្ទាល់ដែលបានយកមកកក់មុន ចំនួន៣០០ដុល្លាអាមេរិក ផងដែរ គឺម្ចាស់ដីស៊ីស៊ីដាច់ប្រាក់កក់នោះ។ ហើយឈ្មោះ [redacted] សាមឌី បានទាមទារយកប្រាក់មកវិញទាំងអស់។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមឌី បានឆ្លើយថា៖ កាលពីថ្ងៃទី



Scanned with CamScanner

២៦ ខែមករា ឆ្នាំ២០២២ ឈ្មោះ [redacted] ជុន ភេទប្រុស អាយុ៤១ឆ្នាំ កាន់អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ ១៨០៧០២៩៨៣ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៧ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិកន្ទួត ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប បានព្រមព្រៀងលក់ដីមកឱ្យខ្លួនចំនួន៣០ហិកតា មានទីតាំងស្ថិតនៅភូមិផ្ទឹកជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប ដោយក្នុង០១ហិកតា មានចំនួន២,៣០០ដុល្លារអាមេរិក។ ដោយមានការអះអាងរបស់ជនត្រូវចោទឈ្មោះ [redacted] ជុន ថាមានដីដូចការអះអាងខាងលើនេះពិតមែនទើបខ្លួនមានការទុកចិត្ត និងបានធ្វើការប្រគល់ប្រាក់ថ្លៃលក់ដីចំនួន៣៧,០០០ដុល្លារអាមេរិក ឱ្យទៅគាត់តាមរយៈកិច្ចសន្យាលក់ដី ទិញដី កក់ប្រាក់ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២។ លុះក្រោយមកទើបខ្លួនបានដឹងថាលោក [redacted] ជុន មិនមានដីលក់ដូចការអះអាងខាងលើមកឱ្យខ្លួនឡើយទើបនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនបានប្ដឹងឈ្មោះ [redacted] ជុន តាមរយៈពាក្យបណ្ដឹងលេខ៤៣ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ និងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ១៤៣៤អយឈ/២២ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប សម្រេចស៊ើបសួរពីបទ រំលោភលើទំនុកចិត្ត ដែលប្រព្រឹត្តនៅភូមិផ្ចិតជ្រុំ ឃុំកន្ទួត ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃឃាត់ខ្លួន។ ដោយនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២ ឈ្មោះ [redacted] ជុន បានផ្ដល់ចម្លើយនៅ ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា ខ្លួនពិតជាបានទទួលប្រាក់ចំនួន ៣៧,០០០(បីម៉ឺនប្រាំពីរពាន់)ដុល្លារអាមេរិក ពីខ្លួននៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិតប្រាកដមែន ដោយឈ្មោះ [redacted] ជុន បានសន្យាថារយៈពេល០៣ថ្ងៃ ក្រោយពីបានទទួលប្រាក់និងយកឯកសារដីទំហំ៣០ហិកតា ដើម្បីធ្វើការផ្ទេរសិទ្ធិកាន់កាប់ដីធ្លីពីម្ចាស់ដើមមកឱ្យខ្លួនវិញ។ ប៉ុន្តែដល់ថ្ងៃកំណត់ខាងលើ ឈ្មោះ [redacted] ជុន មិនគោរពតាមការធានាអះអាង របស់ខ្លួន ឡើយព្រមទាំងមិនបានផ្ដល់ចម្លើយមកខ្លួន និងព្យាយាមគេចវេសពីការទទួលខុសត្រូវថែមទៀត តាមរយៈកំណត់ហេតុស្ដីពីការឃាត់ខ្លួន ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២ របស់ស្នងការនគរបាលខេត្ត សៀមរាប។ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ នៅដំណាក់កាលអយ្យការឈ្មោះ [redacted] ជុន បានធ្វើការ ឆ្លើយបំភ្លឺថាខ្លួនបានទទួលប្រាក់ពីខ្លួនចំនួន២១,០០០ដុល្លារអាមេរិក ដោយក្នុងនោះឈ្មោះ [redacted] ជុន បានយកប្រាក់ចំនួន៣,៥០០ដុល្លារអាមេរិក ទៅកក់ថ្លៃដី។ រីឯប្រាក់ដែលនៅសល់ចំនួន១៥,៧០០ដុល្លារអាមេរិក ឈ្មោះ [redacted] ជុន បានយកទៅទិញដីមួយ កន្លែងទៀតចំនួន៣០ហិកតា មានទីតាំងស្ថិតនៅភូមិខ្នារក្រៅ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប និងដី ចំនួន២ទីតាំង ប៉ុន្តែមិនបានប្រាប់ខ្លួនឱ្យដឹងឡើយ ហើយចំណែកប្រាក់ដែលនៅសល់ឈ្មោះ [redacted] ជុន បាន យកទៅចាយវាយផ្ទាល់ខ្លួនទៅវិញ តាមរយៈកំណត់ហេតុសួរចម្លើយចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ របស់ សាលាដំបូងខេត្តសៀមរាប។ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ នៅចំពោះមុខចៅក្រមស៊ើបសួរ ឈ្មោះ [redacted] ជុន បានធ្វើការឆ្លើយបំភ្លឺ និងបានកែប្រែនូវចម្លើយរបស់ខ្លួន ផ្ទុយពីការពិតទាំងស្រុងដោយបានឆ្លើយថាកម្មវត្ថុ នៃការលក់ទិញដីចំនួន០១កន្លែងទំហំ៣០០,០០០ម៉ែត្រក្រឡា ឬស្មើនិងចំនួន៣០ហិកតា មានទីតាំងស្ថិតនៅភូមិផ្ចិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប មិនមែនជាដី របស់ប្រជាពលរដ្ឋទៅវិញហើយបានអះអាងថាបានទទួលប្រាក់ពីខ្លួនមានចំនួន៤លើក គឺលើកទី១ ទទួល បានចំនួន៥,០០០ដុល្លារអាមេរិក(មិនចាំថ្ងៃទីខែឆ្នាំប្រគល់ទទួលប្រាក់) លើកទី២ ចំនួន២,០០០ដុល្លារអាមេរិក (រំលងមួយអាទិត្យ) លើកទី៣ ចំនួន៤,០០០ដុល្លារអាមេរិក (រំលង១០ថ្ងៃ) និងលើកទី៤ ចំនួន១០,០០០ដុល្លារអាមេរិក (រំលងមួយខែ) ដូច្នេះទឹកប្រាក់សរុបគឺចំនួន២១,០០០ដុល្លារអាមេរិក។ ក្នុងរឿងនេះ ខ្លួនសុំប្ដឹងទាមទារសំណងការខូចខាតជាប្រាក់សរុបចំនួន ៣៧,០០០(បីម៉ឺនប្រាំពីរពាន់)ដុល្លារអាមេរិក និងទាមទារសំណងជម្ងឺចិត្តជាប្រាក់សរុបចំនួន ៣០,០០០(បីម៉ឺន)ដុល្លារអាមេរិក។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សារឿន បានឆ្លើយថា៖ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ មានឈ្មោះ [redacted] ជុន ភេទប្រុស អាយុ៤១ឆ្នាំ មុខរបររកស៊ី រស់នៅភូមិកន្ទួត ឃុំកន្ទួត ស្រុកស្វាយ

Scanned with CamScanner

លើ ខេត្តសៀមរាបបានអះអាងថារូបគេបានស្គាល់ឈ្មោះ [redacted] សាមឌី ដែលជាអ្នកទិញដី ក្រោយមកគឺឈ្មោះ [redacted] ជុន បានទំនាក់ទំនងជាមួយឈ្មោះ [redacted] សាមឌី ដើម្បីទិញដីមួយកន្លែងពីខ្លួនមានទំហំ៣០០០០ម៉ែត្រការ៉េ ក្នុងតម្លៃ៦៩០០០ដុល្លាអាមេរិក មានទីតាំងស្ថិតនៅភូមិផ្លិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើខេត្តសៀមរាប។ ក្រោយមកឈ្មោះ [redacted] ជុន បាននាំខ្លួនទៅជួបឈ្មោះវី និងឈ្មោះ [redacted] សាមឌី ប៉ុន្តែពេលនោះឈ្មោះ [redacted] ជុន ជាអ្នកកំណត់តម្លៃ ដោយគ្រាន់តែរូបខ្លួនមកបញ្ជាក់អះអាងថារូបខ្លួនគឺជាម្ចាស់ដីពិតប្រាកដមែន ចំណែករឿងតម្លៃគឺខ្លួនមិនបានដឹងថាឈ្មោះ [redacted] ជុន ដាក់លក់ក្នុងតម្លៃប៉ុន្មាននោះទេក្រោយ មកឈ្មោះ វី បានទំនាក់ទំនងមកខ្លួនផ្ទាល់សួរនាំថាមានឃើញឈ្មោះ [redacted] ជុន យកប្រាក់មកកក់ថ្លៃដីដែរឬទេ ពេលនោះខ្លួនប្រាប់ថាមិនដឹងនោះទេ ហើយឈ្មោះ វី បានប្រាប់ខ្លួនថាឈ្មោះ [redacted] ជុន បានយកប្រាក់ពីឈ្មោះ [redacted] សាមឌី ចំនួន៣៧០០០ដុល្លាអាមេរិក ដើម្បីយកទៅកក់ថ្លៃដីរបស់ខ្លួន នៅចំណុចនេះខ្លួនសូមឆ្លើយបដិសេធថាខ្លួនពិតជាមិនបានទទួលប្រាក់កក់ចំនួន៣៧០០០ដុល្លាអាមេរិក សំរាប់ថ្លៃដី ខាងលើពីឈ្មោះ [redacted] ជុន នោះទេ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សាវ៉ារី បានឆ្លើយថា៖ កាលពីក្នុងអំឡុងឆ្នាំ ២០២២ ខ្លួនបានដើររកស៊ីទិញដីលក់ដី ជាមួយ និងបងប្រុស [redacted] សាមឌី គាត់ធ្វើជាឈ្មួញ ប្រចាំនៅភូមិស្រែចង្ក្រុត ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ហើយនៅក្នុងពេលនោះឈ្មោះ [redacted] ផន ភេទប្រុស អាយុ ៣៦ឆ្នាំ មានទីលំនៅភូមិស្រែចង្ក្រុត ស្រុកបន្ទាយស្រី បានណែនាំបងប្រុស នាងសាមឌី ឱ្យស្គាល់ឈ្មោះ [redacted] ជុន ដោយពេលនោះឈ្មោះ [redacted] ជុន គេបានអះអាងប្រាប់ថារូបគេមានដី សំរាប់លក់មួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិផ្លិតជ្រុំ ឃុំកន្ទួត ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប ចំនួន៣០ហិកតា ហើយបង [redacted] សាមឌី ក៏បានយល់ព្រមថានិងទិញដីនោះយក ហើយពេលនោះឈ្មោះ [redacted] ជុន បានសុំឱ្យគាត់កក់ប្រាក់មួយចំនួន៣៧០០០ដុល្លាអាមេរិក ហើយគាត់ក៏បានយល់ព្រមតាមសំណើរបស់ឈ្មោះ [redacted] ជុន ប៉ុន្តែនៅពេលដែលរូបគេយកប្រាក់ហើយឈ្មោះ [redacted] ជុន ពុំមានដីសំរាប់លក់ឱ្យឈ្មោះ [redacted] សាមឌី នោះទេ ហើយបានគេចខ្លួនបាត់រហូត។

<u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី</u>

ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការឃើញថា ចំណុចវិវាទនៃរឿងក្តីនេះ គឺចេញពីការក្លែងបន្លំ: និងគេបំបាត់ប្រាក់កក់ថ្លៃទិញដីរបស់កូនក្តីខ្លួនចំនួន៣៧,០០០ដុល្លាអាមេរិក តាមរយៈការយកប្រាក់នោះទៅចាត់ចែង និងប្រើប្រាស់ខុសពីគោលបំណងដែលបានប្រគល់ឱ្យ ដែលប្រព្រឹត្តនៅថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២២ ស្ថិតនៅភូមិកន្ទួត ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប។ អង្គហេតុ អង្គច្បាប់ និងភស្តុតាងដាក់បន្ទុកមានគ្រប់គ្រាន់សម្រាប់ដាក់ជូនតុលាការត្រួតពិនិត្យ វិនិច្ឆ័យ និងជាមូលដ្ឋានក្នុងការសម្រេចសេចក្តីឱ្យស្របតាមកម្មវត្ថុ និងសំណូមពរនៃពាក្យបណ្តឹង និងពាក្យសុំបំភ្លឺបន្ថែម។ ដូច្នេះ ខ្លួនសូមសំណូមពរឱ្យតុលាការមេត្តាសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ជុន តាមច្បាប់ និងសម្រេចឱ្យឈ្មោះ [redacted] ជុន សងសំណងការខូចខាតជាប្រាក់សរុបចំនួន ៣៧,០០០(បីម៉ឺនប្រាំពីរពាន់)ដុល្លាអាមេរិក និងទាមទារសំណងជម្ងឺចិត្តជាប្រាក់សរុបចំនួន ៣០,០០០(បីម៉ឺន)ដុល្លាអាមេរិក តាមការទាមទាររបស់កូនក្តីខ្លួន។

<u>សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ</u>

ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្ត រំលោភលើទំនុកចិត្ត ប្រាកដមែន ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៨ អយឈ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់។

Scanned with CamScanner

<u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ</u>

ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការឃើញថា កូនក្តីខ្លួនទទួលស្គាល់តែចំនួន ២១,០០០ដុល្លាអាមេរិក ទេ។ ដើមបណ្តឹងរដ្ឋប្បវេណី និងកូនក្តីខ្លួនមានទំនាក់ទំនងគ្នាក្នុងរឿងទិញលក់ដី ហើយកូនក្តីខ្លួនជាអ្នកគួកជេរ បានយកលុយពីដើមបណ្តឹងទៅឲ្យម្ចាស់ដីមែន ហើយបានឲ្យដើមបណ្តឹង ប្រគល់ប្រាក់ចំនួន៥០% តែដើមបណ្តឹងពុំបានប្រគល់ប្រាក់ឲ្យតាមការកំណត់ ទើបម្ចាស់ដីរំលាយកិច្ចសន្យាទិញលក់ នេះមិនមែនជាកំហុសរបស់កូនក្តីខ្លួនទេ។ ហេតុនេះ កូនក្តីរបស់ខ្លួនគ្មានចេតនាទុច្ចរិតទេ សុំតុលាការមេត្តាពិចារណា និងសម្រេចឲ្យកូនក្តីរបស់ខ្លួនរួចខ្លួនពីបទចោទប្រកាន់ និងសុំឲ្យបញ្ជូនរឿងនេះជារឿងក្តីរដ្ឋប្បវេណី វិញ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជុន

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមឌី

ក្រោយពីបានស្តាប់អំណានចម្លើយរបស់នានា

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យ ភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>**សំអាងហេតុ**</u>

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៧៩ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០២២ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ ២១០ ពស.ព្រស/ដ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ដែលបានបញ្ជូនជនជាប់ចោទ៖

-ឈ្មោះ [redacted] ជុប ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ មកជំនុំជម្រះពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិផ្ចិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃឃាត់ខ្លួន បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

២-តាមរបាយការណ៍សំយោគលេខ ៣០៣/០២២ ព្រ.ទ.ក.ធ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] ជុប ភេទប្រុស អាយុ៤១ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិផ្ចិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃឃាត់ខ្លួន ប្រាកដមែន។

៣-ជនជាប់ចោទឈ្មោះ [redacted] ជុន បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] សាមឌី ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ តាមរយៈឈ្មោះ [redacted] ដន ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មិនស្គាល់ទីលំនៅពិតប្រាកដបានណែនាំឲ្យស្គាល់ឈ្មោះ [redacted] សាមឌី បន្ទាប់មកនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ខ្លួនបានដឹងថាប្រជាពលរដ្ឋមានលក់ដីមួយកន្លែងទំហំ៣០០,០០០ម៉ែត្រការ៉េស្មើនិង៣០ហិចតា ក្នុងតម្លៃ២៣០០ដុល្លាអាមេរិក ក្នុងមួយហិកតាសរុបទឹកប្រាក់ចំនួន៦៩,០០០ដុល្លាអាមេរិក ហើយឈ្មោះ [redacted] សាមឌី ក៏បានយល់ព្រមទិញដីខាងលើដោយខ្លួនបានតម្រូវឲ្យឈ្មោះ [redacted] សាមឌីប្រគល់ប្រាក់មកខ្លួនលើកទី១ ចំនួន៥,០០០ដុល្លាអាមេរិក ដោយខ្លួនមិនបានចាំថ្ងៃខែឆ្នាំប្រគល់នោះទេ។ នៅពេលដែលខ្លួនបានទទួលប្រាក់លើកទី១ ចំនួន ៥,០០០ ដុល្លាអាមេរិក ពីឈ្មោះ [redacted] សាមឌី ខ្លួនបានយកទៅកក់ឲ្យម្ចាស់ដីឈ្មោះ លុន ហើយម្ចាស់ដីឈ្មោះ

Scanned with CamScanner

លុន បានតម្រូវឱ្យខ្លួនធ្វើយ៉ាងណាឱ្យកក់បានចំនួន៥០ភាគរយ ក្នុងរយៈពេល១ខែកន្លះ ខ្លួនបានប្រាប់ឈ្មោះ [redacted] សាមឌី ពីរឿងការបង់នោះរួចហើយ។ រំលងបាន១អាទិត្យ ឈ្មោះ [redacted] សាមឌី បានយកប្រាក់មកឱ្យខ្លួនលើកទី២ ចំនួន២,០០០ដុល្លារអាមេរិក ដើម្បីយកទៅឱ្យម្ចាស់ដី ហើយម្ចាស់ដីមិនព្រមទទួលយក ខ្លួនក៏បានរាយការណ៍ប្រាប់ឈ្មោះ [redacted] សាមឌី ពីរឿងនិងរួចហើយដែរ ដោយម្ចាស់ដីថាបើមិនបាន៥០ភាគរយ មិនទទួលយកទេ ក្រោយមករំលងបាន១០ថ្ងៃ ឈ្មោះ [redacted] សាមឌី បានយកប្រាក់មកឱ្យខ្លួនជាលើកទី៣ ចំនួន៤,០០០ដុល្លាអាមេរិក ខ្លួនបានយកប្រាប់នោះទៅឱ្យម្ចាស់ដីមិនទទួលយកទេ ដោយទាមទារឱ្យបានចំនួន៥០ភាគរយ ទើបយកខ្លួនបានរាយការណ៍ជូនឈ្មោះ [redacted] សាមឌី រួចហើយដែរ។ ហើយរំលងរយៈពេល១ខែទើបឈ្មោះ [redacted] សាមឌី បានយកប្រាក់មកឱ្យខ្លួនជាលើកទី៤ ចំនួន១០,០០០ដុល្លាអាមេរិក ខ្លួនបានយកប្រាក់លើកទី២ លើកទី៣ និងលើកទី៤ សរុបចំនួន១៦,០០០ដុល្លាអាមេរិក ឱ្យទៅម្ចាស់ដីឈ្មោះ លុន តែគាត់មិនព្រមយកទេ ដោយម្ចាស់និយាយថាផុតរយៈពេលបង់ចំនួន៥០ភាគរយ នោះហើយម្ចាស់ដីបាននិយាយថាគាត់ឈប់លក់ទៀតហើយ ហើយចំពោះប្រាក់កក់លើកទី១ ចំនួន៥,៣០០ដុល្លាអាមេរិកបូកនឹងប្រាក់ដែលជាលុយខ្លួនផ្ទាល់ដែលបានយកមកកក់មុន ចំនួន៣០០ដុល្លាអាមេរិក ផងដែរ គឺម្ចាស់ដីសុំស៊ីដាច់ប្រាក់កក់នោះ។ ហើយឈ្មោះ [redacted] សាមឌី បានទាមទារយកប្រាក់មកវិញទាំងអស់។

៤-ជនជាប់ចោទឈ្មោះ [redacted] ជុន បានឆ្លើយនៅកំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា៖ កាលពីអំឡុងខែមករា ឆ្នាំ២០២២ ឈ្មោះ [redacted] សាមឌី បានពឹងពាក់ខ្លួនឱ្យជួយរកទិញដីចំនួន៣០ហិកតា ក្រោយមកខ្លួនបានរកដីពីប្រជាពលរដ្ឋបានចំនួន ៣០ហិកតា ស្មើនឹង៣០០,០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិផ្អិកជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប ដើម្បីលក់ឱ្យទៅឈ្មោះ [redacted] សាមឌី ក្នុងតម្លៃ២៣០០ដុល្លាអាមេរិកក្នុងមួយហិកតា សរុបទឹកប្រាក់ចំនួន៦៩,០០០ដុល្លាអាមេរិក ដោយខ្លួនបានតម្រូវឱ្យឈ្មោះ [redacted] សាមឌី ប្រគល់ប្រាក់ជាមុនដើម្បីយកទៅកក់ថ្លៃដី ចំនួន៤លើក សរុបទាំងអស់ចំនួន២១,០០០ដុល្លាអាមេរិក។ ខ្លួនបានយកប្រាក់ចំនួន៥,៣០០ដុល្លាអាមេរិក ទៅកក់ឱ្យថ្លៃដីរបស់ប្រជាពលរដ្ឋ(មិនចាំឈ្មោះ) ប្រាក់នេះកក់ហើយក៏ដាច់ ចំណែកប្រាក់នៅសល់ គឺខ្លួនបានយកទៅចាយវាយផ្ទាល់ខ្លួនអស់ ហើយមិនបានយកទៅកក់ថ្លៃដីឱ្យឈ្មោះ [redacted] សាមឌី ដូចអ្វីដែលខ្លួនបានអះអាងចំពោះឈ្មោះ [redacted] សាមឌី ឡើយ។

៥-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមឌី បានឆ្លើយថា៖ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ឈ្មោះ [redacted] ជុន ភេទប្រុស អាយុ៤១ឆ្នាំ កាន់អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ ១៨០៧០២៩៩៣ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៧ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិកន្ទួត ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប បានព្រមព្រៀងលក់ដីមកឱ្យខ្លួនចំនួន៣០ហិកតា មានទីតាំងស្ថិតនៅភូមិផ្អិកជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប ដោយក្នុង០១ហិកតា មានចំនួន ២,៣០០ដុល្លាអាមេរិក។ ដោយមានការអះអាងរបស់ជនត្រូវចោទឈ្មោះ [redacted] ជុន ថាមានដីដូចការអះអាងខាងលើនេះពិតមែនទើបខ្លួនមានការទុកចិត្ត និងបានធ្វើការប្រគល់ប្រាក់ថ្លៃលក់ដីចំនួន៣៧,០០០ដុល្លាអាមេរិក ឱ្យទៅគាត់តាមរយៈកិច្ចសន្យាលក់ដី ទិញដីកក់ប្រាក់ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២។ លុះក្រោយមកទើបខ្លួនបានដឹងថាលោក [redacted] ជុន មិនមានដីលក់ដូចការអះអាងខាងលើមកឱ្យខ្លួនឡើយទើបនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនបានប្តឹងឈ្មោះ [redacted] ជុន តាមរយៈពាក្យបណ្តឹងលេខ៤៣ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ និងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ១៤៣៤អយឈ/២២ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តសៀមរាប សម្រេចស៊ើបសួរពីបទ រំលោភលើទំនុកចិត្ត ដែលប្រព្រឹត្តនៅភូមិផ្អិតជ្រុំ ឃុំកន្ទួត ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃឃាត់ខ្លួន។ ដោយនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២ ឈ្មោះ [redacted] ជុន បានផ្តល់ចម្លើយនៅ ចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា ខ្លួនពិតជាបានទទួល

Scanned with CamScanner

ប្រាក់ចំនួន ៣៧,០០០(បីម៉ឺនប្រាំពីរពាន់)ដុល្លាអាមេរិក ពីខ្លួននៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ពិតប្រាកដមែន ដោយឈ្មោះ [redacted] ជុន បានសន្យាថារយៈពេល០៣ថ្ងៃ ក្រោយពីបានទទួលប្រាក់និងយកឯកសារដីទំហំ៣០ ហិកតា ដើម្បីធ្វើការផ្ទេរសិទ្ធិកាន់កាប់ដីធ្លីពីម្ចាស់ដើមមកឱ្យខ្លួនវិញ។ ប៉ុន្តែដល់ថ្ងៃកំណត់ខាងលើឈ្មោះ [redacted] ជុន មិនគោរពតាមការធានាអះអាង របស់ខ្លួន ឡើយព្រមទាំងមិនបានផ្តល់ចម្លើយមកខ្លួន និងព្យាយាមគេចវេសពីការទទួលខុសត្រូវថែមទៀត តាមរយៈកំណត់ហេតុស្តីពីការឃាត់ខ្លួន ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២ របស់ស្នងការនគរបាលខេត្ត សៀមរាប។ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ នៅដំណាក់កាលអយ្យការឈ្មោះ [redacted] ជុន បានធ្វើការ ឆ្លើយបំភ្លឺថាខ្លួនបានទទួលប្រាក់ពីខ្លួនចំនួន២១,០០០ដុល្លាអាមេរិក ដោយក្នុងនោះឈ្មោះ [redacted] ជុន បានយកប្រាក់ចំនួន៣,៥០០ដុល្លាអាមេរិក ទៅកក់ថ្លៃដី។ រីឯប្រាក់ដែលនៅ សល់ចំនួន១៥,៧០០ ដុល្លាអាមេរិក ឈ្មោះ [redacted] ជុន បានយកទៅទិញដីមួយ កន្លែងទៀតចំនួន៣០ហិកតា មានទីតាំងស្ថិតនៅភូមិខ្នារក្រៅ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប និងដី ចំនួន២ទីតាំង ប៉ុន្តែមិនបានប្រាប់ខ្លួនឲ្យដឹងឡើយ ហើយចំណែកប្រាក់ដែលនៅសល់ឈ្មោះ [redacted] ជុន បាន យកទៅចាយវាយផ្ទាល់ខ្លួនទៅវិញ តាមរយៈកំណត់ហេតុសួរចម្លើយចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ របស់ សាលាដំបូងខេត្តសៀមរាប។ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ នៅចំពោះមុខចៅក្រមស៊ើបសួរ ឈ្មោះ [redacted] ជុន បានធ្វើការឆ្លើយបំភ្លឺ និងបានកែប្រែនូវចម្លើយរបស់ខ្លួន ផ្ទុយពីការពិតទាំងស្រុងដោយបានឆ្លើយថាកម្មវត្ថុ នៃការលក់ទិញដីចំនួន០១កន្លែងទំហំ៣០០,០០០ ម៉ែត្រក្រឡា ឬស្មើនិងចំនួន៣០ហិកតា មានទីតាំងស្ថិតនៅភូមិផ្អិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប មិនមែនជាដី របស់ប្រជាពលរដ្ឋទៅវិញហើយបានអះអាងថាបានទទួលប្រាក់ពីខ្លួនមានចំនួន៤លើក គឺលើកទី ១ ទទួល បានចំនួន៥,០០០ដុល្លាអាមេរិក(មិនចាំថ្ងៃទីខែឆ្នាំប្រគល់ទទួលប្រាក់) លើកទី២ ចំនួន២,០០០ដុល្លាអាមេរិក (រំលងមួយអាទិត្យ) លើកទី៣ ចំនួន៤,០០០ដុល្លាអាមេរិក (រំលង១០ថ្ងៃ) និងលើកទី៤ ចំនួន ១០,០០០ដុល្លាអាមេរិក (រំលងមួយខែ) ដូច្នេះទឹកប្រាក់សរុបគឺចំនួន២១,០០០ដុល្លាអាមេរិក។ ក្នុងរឿងនេះ ខ្លួនសុំប្តឹងទាមទារសំណងការខូចខាតជាប្រាក់សរុបចំនួន ៣៧,០០០(បីម៉ឺនប្រាំពីរពាន់)ដុល្លាអាមេរិក និងទាមទារសំណងជម្ងឺចិត្តជាប្រាក់សរុបចំនួន ៣០,០០០(បីម៉ឺន)ដុល្លាអាមេរិក។

៦-សាក្សីឈ្មោះ [redacted] សារឿន បានឆ្លើយថា៖ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ មានឈ្មោះ [redacted] ជុន ភេទប្រុស អាយុ៤១ឆ្នាំ មុខរបររកស៊ី រស់នៅភូមិកន្ទួត ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប បានអះអាងថារូបគេបានស្គាល់ឈ្មោះ [redacted] សាមឌី ដែលជាអ្នកទិញដី ក្រោយមកគឺឈ្មោះ [redacted] ជុន បានទំនាក់ទំនងជាមួយឈ្មោះ [redacted] សាមឌី ដើម្បីទិញដីមួយកន្លែងពីខ្លួនមានទំហំ៣០០០០ម៉ែត្រការ៉េ ក្នុងតម្លៃ ៦៩០០០ដុល្លាអាមេរិក មានទីតាំងស្ថិតនៅភូមិផ្អិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើខេត្តសៀមរាប។ ក្រោយមក ឈ្មោះ [redacted] ជុន បាននាំខ្លួនទៅជួបឈ្មោះ វី និងឈ្មោះ [redacted] សាមឌី ប៉ុន្តែពេលនោះឈ្មោះ [redacted] ជុន ជាអ្នកកំណត់តម្លៃ ដោយគ្រាន់តែរូបខ្លួនមកបញ្ជាក់អះអាងថា រូបខ្លួនគឺជាម្ចាស់ដីពិតប្រាកដមែន ចំណែករឿងតម្លៃគឺខ្លួនមិនបានដឹងថាឈ្មោះ [redacted] ជុន ដាក់លក់ក្នុងតម្លៃប៉ុន្មាននោះទេក្រោយ មកឈ្មោះ វី បានទំនាក់ទំនងមកខ្លួនផ្ទាល់សួរនាំថាមានឃើញឈ្មោះ [redacted] ជុន យកប្រាក់មកកក់ថ្លៃដីដែរឬទេ ពេលនោះខ្លួនប្រាប់ថាមិនដឹងនោះទេ ហើយឈ្មោះ វី បានប្រាប់ខ្លួនថាឈ្មោះ [redacted] ជុន បានយកប្រាក់ពីឈ្មោះ [redacted] សាមឌី ចំនួន៣៧០០០ដុល្លាអាមេរិក ដើម្បីយកទៅកក់ថ្លៃដីរបស់ខ្លួន នៅចំណុចនេះខ្លួនសូមឆ្លើយបដិសេធថាខ្លួនពិតជាមិនបានទទួលប្រាក់កក់ចំនួន៣៧០០០ដុល្លាអាមេរិក សំរាប់ថ្លៃដី ខាងលើពីឈ្មោះ [redacted] ជុន នោះទេ។

៧-សាក្សីឈ្មោះ [redacted] សារ៉ាវី បានឆ្លើយថា៖ កាលពីក្នុងអំឡុងឆ្នាំ២០២២ ខ្លួនបានដើររកស៊ីទិញដីលក់ដីជាមួយ និងបងប្រុស [redacted] សាមឌី គាត់ធ្វើជាយោធា ប្រចាំនៅភូមិស្រែចង្ហុត ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ហើយនៅក្នុងពេលនោះឈ្មោះ [redacted] ជុន ភេទប្រុស អាយុ៣៦ឆ្នាំ មានទីលំនៅភូមិ

Scanned with CamScanner

ស្រែចង្កូត ស្រុកបន្ទាយស្រី បានណែនាំបងប្រុស នាងសាមឌី ឱ្យស្គាល់ឈ្មោះ [redacted] ជុន ដោយពេលនោះឈ្មោះ [redacted] ជុន គេបានអះអាងប្រាប់ថារូបគេមានដី សំរាប់លក់មួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិផ្ចិតជ្រុំឃុំកន្ទួត ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប ចំនួន៣០ហិកតា ហើយបង [redacted] សាមឌី ក៏បានយល់ព្រមថានឹងទិញដីនោះយក ហើយពេលនោះឈ្មោះ [redacted] ជុន បានសុំឱ្យគាត់កក់ប្រាក់មួយចំនួន៣៧០០០ដុល្លាអាមេរិក ហើយគាត់ក៏បានយល់ព្រមតាមសំណើរបស់ឈ្មោះ [redacted] ជុន ប៉ុន្តែនៅពេលដែលរូបគេយកប្រាក់ហើយឈ្មោះ [redacted] ជុន ពុំមានដីសំរាប់លក់ឱ្យឈ្មោះ [redacted] សាមឌី នោះទេ ហើយបានគេចខ្លួនបាត់រហូត។

៨-ជនជាប់ចោទបានឆ្លើយទទួលស្គាល់ថាបានទទួលប្រាក់ចំនួន២១,០០០ដុល្លាអាមេរិក ពីដើមបណ្តឹងរដ្ឋប្បវេណី ហើយបានយកប្រាក់ចំនួន ៥,៣០០ដុល្លាអាមេរិក ទៅកក់ថ្លៃដី ម្ចាស់ដីទាមទារឱ្យបង់ប្រាក់៥០%នៃថ្លៃដី តែដោយសារតែដើមបណ្តឹងរដ្ឋប្បវេណី មិនប្រគល់ប្រាក់ឱ្យ ទើបកិច្ចសន្យាទិញលក់ដីត្រូវរំលាយ ហើយដាច់ប្រាក់កក់ដែលបានបង់នោះ ប៉ុន្តែផ្អែកតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សារឿន ជាម្ចាស់ដី បានឆ្លើយបដិសេធថា មិនបានទទួលប្រាក់កក់ពីជនជាប់ចោទសម្រាប់ថ្លៃដីនោះទេ ដែលបង្ហាញថា ចម្លើយរបស់ជនជាប់ចោទគ្រាន់តែជាចម្លើយឆ្លើយដោះបន្ទុកប៉ុណ្ណោះ ដោយជនជាប់ចោទពុំមានសាក្សី ឬភស្តុតាងជាឯកសារណាមួយមកបញ្ជាក់ដើម្បីដោះបន្ទុកពីការចោទប្រកាន់ឡើយ។ ម្យ៉ាងទៀតតាមចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ឆ្លើយថា ប្រាក់ដែលនៅសល់ពីកក់ដី គឺបានយកទៅចាយវាយផ្ទាល់ខ្លួនអស់ ហើយមិនបានយកទៅកក់ថ្លៃដី ដូចអ្វីដែលបានអះអាងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ឡើយ ដែលបង្ហាញថា ជនជាប់ចោទពិតជាមានចេតនាគៃបំបាត់មូលនិធិរបស់ជនរងគ្រោះ ដែលបានប្រគល់ឱ្យដើម្បីយកប្រាក់នោះទៅទិញដី តែមិនយកទៅទិញដី ហើយយកចាយវាយខ្លួនឯង។

៩-តាមចម្លើយរបស់ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងរបាយការណ៍របស់សមត្ថកិច្ចព្រមទាំងឯកសារជាភស្តុតាងមានលក្ខណៈស៊ីសង្វាក់គ្នាបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] ជុប ពិតជាបានប្រព្រឹត្តអំពើ រំលោភលើទំនុកចិត្ត កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២រហូតដល់ថ្ងៃឃាត់ខ្លួន ប្រាកដមែន។

១០-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ជុប ដែលបានយកប្រាក់របស់ជនរងគ្រោះប្រគល់ឱ្យដើម្បីយកទៅកក់ដី មិនព្រមយកទៅកក់ ដោយយកប្រាក់នោះមកចាយវាយ កក់ និងទិញដី៣កន្លែងមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនឯងទៅវិញ ត្រូវច្បាប់កំណត់ថា ជាបទល្មើស រំលោភលើទំនុកចិត្ត ហើយបញ្ញត្តិឱ្យផ្តន្ទាទោស ពី៦(ប្រាំមួយ)ខែ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០(មួយលាន)រៀល ទៅ ៦,០០០,០០០(ប្រាំមួយលាន)រៀល តាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

១១-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ និងសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយល្អក្នុងសង្គម ដែលច្បាប់ហាមឃាត់ជាពិសេសបានបំពានទៅនឹងមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

១២-ជនជាប់ចោទជានីតិជន ដែលមានសមត្ថភាពស្មារតីគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដែលបានប្រព្រឹត្ត។

១៣-មានបន្ទុក និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ជុប ភេទប្រុស អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ ពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិផ្ចិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃឃាត់ខ្លួន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

១៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមឌី ប្តឹងទាមទារសំណងជាប្រាក់ចំនួន ៣៧,០០០

Scanned with CamScanner

(បីម៉ឺនប្រាំពីរពាន់)ដុល្លារអាមេរិក និងទាមទារសំណងជម្ងឺចិត្តជាប្រាក់សរុបចំនួន ៣០,០០០(បីម៉ឺន)ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ ឃើញថាបណ្តឹងនេះធ្វើឡើងមានលក្ខណៈត្រឹមត្រូវ តាមមាត្រា១៣,១៤,១៥, ២១,២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការព្រហ្មទណ្ឌអាចពិនិត្យ និងសម្រេចបានតាមមាត្រា២៣, ៣៥,៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តាមការពិនិត្យឃើញថា ការទាមទារ របស់ដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនច្រើន ដោយគប្បីតុលាការបន្ធូរបន្ថយមួយផ្នែកឱ្យបានសមស្របទៅនឹងទំហំនៃព្យសនកម្ម និងស្ថានភាពសេដ្ឋកិច្ចរបស់ជនជាប់ចោទ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ផ្តន្ទាទោសឈ្មោះ [redacted] ជុន ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១,០០០,០០០(មួយលាន)រៀល ពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិផ្អិតជ្រុំ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃឃាត់ខ្លួន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

២-ឱ្យឈ្មោះ [redacted]ជុន សងសំណងការខូចការជាប្រាក់សរុបចំនួន ៣៧,០០០(បីម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តជាប្រាក់សរុបចំនួន ៥,០០០(ប្រាំពាន់)ដុល្លារអាមេរិក មកឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សាមឌី ។ ការទាមទារលើសពីនេះបដិសេធចោល។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ជុប និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមឌី ។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី ០៩ ខែ ១០ ឆ្នាំ២០២៣
ក្រឡាបញ្ជី

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៧កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

សៀមរាប ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner